Australian Government
Department of Home Affairs

# មណ្ឌលសហគមន៍

## ការកែប្រែសេវាកម្មដោយសារកូវីដ-19

ជំនួយគាំពារក្រោមកម្មវិធីមណ្ឌលសហគមន៍នៅតែមានបន្តសម្រាប់អតិថិជនក្នុងអំឡុងពេលកូវីដ-19 រាតត្បាត។ តែរបៀបផ្តល់សេវានេះអាចមានការកែប្រែអាស្រ័យទៅលើឱវាទផ្លូវការរបស់វិស័យសុខាភិបាល។

នៅមណ្ឌលសហគមន៍ភាគច្រើន មានការថយចុះនូវការជួបប្រាស្រ័យដោយផ្ទាល់។
ប្រធានមណ្ឌលរក្សាការប្រាស្រ័យទាក់ទងជាមួយអតិថិជននីមួយៗតាមរយៈទូរស័ព្ទ។
ការជួបជាក្រុមៗនឹងបែរទៅធ្វើតាមអនឡាញវិញ
ដើម្បីធានាឲ្យសហគមន៍ទាំងឡាយនៅតែមានទំនាក់ទំនងជាមួយប្រធានមណ្ឌលសហគមន៍ ជាមួយគ្នានិងគ្នា ហើយបន្តចូលរួមក្នុងសកម្មភាព សំខាន់ៗ មានដូចជាថ្នាក់រៀនសន្ទនាភាសាអង់គ្លេសជាដើម។

ស្វែងយល់អំពី **កូវីដ-19 និងរោគសញ្ញារបស់វា**។

## តើមណ្ឌលសហគមន៍ជាអ្វី ?

មណ្ឌលសហគមន៍ (គេក៏ហៅថាកម្មវិធីមណ្ឌលសហគមន៍ថ្នាក់ជាតិផងដែរ) គឺជាកន្លែងស្វាគមន៍ក្រុមគ្រួសារជនអន្តោប្រវេសន៍និងជនភៀសខ្លួន ជាពិសេសម្តាយនិងកូនតូចៗ។

មណ្ឌលសហគមន៍ស្ថិតនៅក្នុងសាលាបឋមសិក្សា ហើយជួយពលរដ្ឋក្នុងការរៀនភាសាអង់គ្លេស រៀនជំនាញថ្មី ស្វែងរកការងារធ្វើ ហើយនិងផ្តល់ជំនួយក្នុងការទៅពឹងពាក់សេវាគាំពារនានារបស់រដ្ឋាភិបាល។

## តើមណ្ឌលសហគមន៍មាននៅទីណាខ្លះ ?

- រដ្ឋញូសៅវ៉េល្ស (NSW) ៖ Parramatta, Blacktown, Canterbury Bankstown, Fairfield, Cumberland, Wollongong, Liverpool
- រដ្ឋវិកថូរៀ (VIC) ៖ Brimbank, Dandenong, Hume, Banyule, Geelong, Shepparton
- រដ្ឋឃ្វីនស៍ឡែនដ៍ (QLD) ៖ Logan, Ipswich
- រដ្ឋអូស្ត្រាលីខាងត្បូង (SA) ៖ Port Adelaide – Enfield, Salisbury

គេអាចមើលតារាងសាលាបឋមសិក្សាដែលមានមណ្ឌលសហគមន៍និងព័ត៌មានទំនាក់ទំនងនៅ **ទីនេះ**។

## តើសេវាកម្មអ្វីខ្លះដែលមណ្ឌលសហគមន៍ផ្តល់ជូន ?

សេវាកម្មដែលមានផ្តល់ គឺខុសៗគ្នារវាងមណ្ឌលសហមន៍មួយនិងមណ្ឌលសហគមន៍មួយទៀត ដើម្បីធានាឲ្យគេអាចបំពេញសេចក្តីត្រូវការរបស់សហគមន៍ក្នុងមូលដ្ឋានរបស់គេ។ ឧទាហរណ៍អំពីប្រភេទនៃសកម្មភាពមានដូចតទៅ ៖

- ក្រុមកុមារប្រជុំគ្នាលេង និងកម្មវិធីសម្រាប់កុមារមានអាយុមុនចូលសាលា
- ថ្នាក់រៀនភាសាអង់គ្លេស និងកម្មវិធីសន្ទនាភាសាអង់គ្លេស
- របៀបរបបរស់នៅប្រកបដោយសុខភាពល្អ និងសិក្ខាសាលា ក៏ដូចជាក្រុមបង្ហាត់ជំនាញបំណិនជីវិត ដទៃៗទៀត
- ការនាំឲ្យមាតាបិតាជួបជុំប្រស្រ័យទាក់ទង ហើយនិងកម្មវិធីកសាងសមត្ថភាព
- កម្មវិធីរៀនភាសានិងរៀនសរសេរព្រមទាំងរៀនអានសម្រាប់កុមារ
- ឱកាសស្ម័គ្រចិត្តធ្វើការ និងការជួយរកការងារ
- ការហ្វឹកហាត់វិជ្ជាជីវៈជាផ្លូវការដោយមានការធ្វើការជាមួយសាលា TAFE និងស្ថាប័នបណ្តុះបណ្តាលដែលមានក្របខ័ណ្ឌ
- សិក្ខាសាលាបណ្តុះបណ្តាលជំនាញក្រៅប្រព័ន្ធ
- ក្រុមអ្នកមានចំណាប់អារម្មណ៍ពិសេស និងក្រុមជួបជុំពិសេស
- ការធ្វើដំណើរជាក្រុមទៅកន្លែងផ្សេងៗតាមកម្មវិធីសិក្សា
- ការបញ្ជូនឈ្មោះទៅកម្មវិធីឯទៀតៗដែលអាចជួយដោះស្រាយបញ្ហា

## តើខ្ញុំមានសិទ្ធិទទួលសេវាកម្មឬទេ ?

គ្រប់ជនអន្តោប្រវេសន៍ទាំងអស់ត្រូវបានស្វាគមន៍នៅមណ្ឌលសហគមន៍។
មានការផ្តោតអារម្មណ៍ចំពោះម្តាយនិងកូនដែលជាជនអន្តោប្រវេសន៍។

## តើខ្ញុំអាចស្វែងរកព័ត៌មានថែមទៀតដោយវិធីណាអំពីសេវាកម្មរបស់មណ្ឌលសហគមន៍?

បើលោកអ្នកចង់បានព័ត៌មានបន្ថែម សូមចូលទៅគេហទំព័រ **មណ្ឌលសហគមន៍** ឬទូរស័ព្ទទៅលេខ 03 8614 3430។